**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

វគ្គអប់រំនយោបាយកម្រិត II

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និងវឌ្ឍនភាពសង្គម

ថ្ងៃពុធ ១៤រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០២៥

# អំពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការគណបក្ស ក្រសួង ស្ថាប័ន រាជធានី ខេត្ត

មាត្រាទី ១១ នៃលក្ខន្តិកៈគណបក្សប្រជាជនកម្ពុជាចែងថា : *អង្គការចាត់តាំងរបស់គណបក្ស ត្រូវបានចាត់តាំងឡើងនៅតាមស្ថាប័ននានា ។ ខ្សែរយៈចាត់តាំងរបស់គណបក្សរួមមាន ៤ថ្នាក់គឺ* :

- *ថ្នាក់កណ្តាល*
- *ថ្នាក់រាជធានី ខេត្ត ក្រសួង ស្ថាប័ន*
- *ថ្នាក់ក្រុង ស្រុក ខណ្ឌ*
- *ថ្នាក់មូលដ្ឋាន*

ឯកសារនេះប្រមូលផ្តុំចងក្រងនូវគោលការណ៍នានារបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលដែលចែងអំពីអង្គការចាត់តាំងគណបក្សថ្នាក់រាជធានី ខេត្ត ក្រសួង ស្ថាប័ន ដែលជាអង្គការចាត់តាំងគណបក្សចំណុះផ្ទាល់ក្រោមការដឹកនាំរបស់គណៈកម្មាធិការកណ្តាល ។

## I. អំពីតួនាទី

ក- **គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត** គឺជាអង្គការដឹកនាំរបស់គណបក្សក្នុងចន្លោះពីមហាសន្និបាតមួយ ទៅមហាសន្និបាតមួយទៀតនៃគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ។ គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ស្ថិតក្រោមការដឹកនាំផ្ទាល់របស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល និងមានការទទួលខុសត្រូវចំពោះមុខគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល និងគណបក្សថ្នាក់ខ្លួន ក្នុងការដឹកនាំ ត្រួតពិនិត្យការអនុវត្តគ្រប់វិស័យការងាររបស់គណបក្ស ដើម្បីសម្រេចភារកិច្ចនយោបាយដែលគណបក្សថ្នាក់លើបានកំណត់ និងសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតថ្នាក់ខ្លួន ។

គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ត្រូវបានបង្កើតនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ លើកលែងតែនៅក្នុងស្ថាប័នសាសនា តុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ ។

ខ- អនុវត្តតាមគោលការណ៍ច្បាប់ស្តីពីគណបក្សនយោបាយ ជំពូកទី ៣ មាត្រា ១៥ ដែលបានចែងថា : *បុព្វជិត មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ អាចចូលរួមជាសមាជិកគណបក្សនយោបាយនានាបាន តែមិនត្រូវធ្វើសកម្មភាពគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយឡើយ ។ គណបក្សនយោបាយមិនត្រូវរៀបចំរចនាសម្ព័ន្ធចាត់តាំងក្នុងស្ថាប័នសាសនា តុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិទេ ។*គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលមានគោលការណ៍ណែនាំជាបន្តបន្ទាប់តាំងពីឆ្នាំ ១៩៩៧ មក អំពីការរំសាយអង្គការចាត់តាំងគណបក្សនៅក្នុងស្ថាប័នដែលច្បាប់ហាមឃាត់ និងផ្ទេរជីវភាពសមាជិកគណបក្សឲ្យទៅចូលរួមជីវភាពគណបក្សនៅក្នុងអង្គការចាត់តាំងគណបក្សនៅតាមមូលដ្ឋាននានា ស្របតាមលក្ខន្តិកៈគណបក្ស ។

មាត្រា ៨៣ ជំពូកទី ៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានចែងថា : *បន្ទាប់ពីម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងការងារ ឬមិនស្ថិតក្នុងពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការអាចចូលរួមក្នុងសកម្មភាពគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន មិនត្រូវមានអាវុធជាប់នឹងខ្លួន និងមិនត្រូវធ្វើអ្វីដែលនាំឲ្យមានការគំរាមកំហែងឡើយ ។*

ដើម្បីបម្រើសំណូមពរនៃការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីនៅក្នុងអង្គការតុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ គណបក្សបានសម្រេចបង្កើតគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះគណៈកម្មាធិការនៃគណបក្ស ៣ ថ្នាក់ ដែលរួមមានថ្នាក់កណ្តាល ថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ។

**<u>គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្តាល</u>** មានតួនាទីជាជំនួយការជូនគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ក្នុងការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីនៅក្នុងអង្គការតុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ ។

គ- **<u>ក្រុមការងារគណបក្សចុះមូលដ្ឋាន</u>** មានតួនាទីជាចម្បងក្នុងការកសាង និងពង្រឹងមូលដ្ឋាននយោបាយរបស់គណបក្សឲ្យបានរឹងមាំនៅគ្រប់មូលដ្ឋាន ដើម្បីគណបក្សរក្សាបានតួនាទីក្នុងការដឹកនាំគ្រប់គ្រងប្រទេសជាតិរយៈពេលយូរអង្វែង តាមរយៈផែនការដណ្តើមបានជោគជ័យឲ្យបានដាច់ខាតគ្រប់ការបោះឆ្នោត តាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ទាំងការបោះឆ្នោតនៅថ្នាក់ជាតិ និងការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ ។

II. **<u>អំពីភារកិច្ច</u>**

ក- **<u>គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន</u>** មានភារកិច្ច ៦ គឺ :

១. ផ្អែកលើលក្ខន្តិកៈ កម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយ សេចក្តីសម្រេចនានារបស់គណៈកម្មាធិការកណ្តាល ច្បាប់បញ្ញត្តិជាធរមានរបស់រដ្ឋ និងសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតគណបក្សថ្នាក់ខ្លួន ដើម្បីកំណត់ទិសដៅ ភារកិច្ច គោលការណ៍ និងវិធានការចាត់តាំងអនុវត្តឲ្យបានសមស្របតាមសភាពការណ៍ជាក់ស្តែងរបស់ក្រសួង ស្ថាប័ន ព្រមទាំងដឹកនាំអង្គការមូលដ្ឋានរបស់គណបក្សអនុវត្តឲ្យបានជោគជ័យ ។

២. បំផុសលើកទឹកចិត្តដល់សមាជិកគណបក្ស និងមន្ត្រី បុគ្គលិក កម្មករ ឲ្យខិតខំប្រឹងប្រែងសម្រេចរាល់ភារកិច្ចរបស់ក្រសួង ស្ថាប័ន ព្រមទាំងចូលរួមគាំទ្រ និងអនុវត្តកម្មវិធីនយោបាយ គោលការណ៍ សេចក្តីសម្រេចនានារបស់គណបក្ស ។

៣. ដឹកនាំ និងត្រួតពិនិត្យអង្គការមូលដ្ឋានរបស់គណបក្សក្នុងការអនុវត្តការងារនយោបាយ សតិអារម្មណ៍ ចាត់តាំង និងចលនាមហាជន ។ ទន្ទឹមនេះត្រូវបង្កលក្ខណៈជួយឧបត្ថម្ភដល់អង្គការសង្គម និងក្រុមការងាររបស់គណបក្សដែលចាត់តាំងឡើងក្នុងក្រសួង ស្ថាប័ន ឲ្យធ្វើសកម្មភាពបានត្រឹមត្រូវតាមតួនាទី ភារកិច្ចរបស់ខ្លួន និងមានប្រសិទ្ធភាព ។

៤. លើកឡើងនូវគោលការណ៍ និងវិធានការដើម្បីជំរុញការងារគ្រប់គ្រង ពង្រឹងពង្រីកសមាជិកគណបក្សសំដៅជានាបានទាំងបរិមាណ និងគុណភាព ។

ចំពោះសមាជិកគណបក្សជាមន្ត្រីជំនាញរបស់ក្រសួង ស្ថាប័ន ដែលឈរជើងបំពេញភារកិច្ចការងារនៅមូលដ្ឋាន ត្រូវចូលរួមជីវភាពគណបក្សនៅក្នុងអង្គការចាត់តាំងរបស់គណបក្សចំណុះគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

៥. ត្រួតពិនិត្យសមាជិក និងអង្គការចាត់តាំងគណបក្សក្នុងការអនុវត្តលក្ខន្តិកៈគណបក្ស គោលការណ៍ គោលនយោបាយ សេចក្តីសម្រេចនានារបស់គណបក្ស និងត្រួតពិនិត្យហិរញ្ញវត្ថុរបស់គណបក្ស ។

៦. ចាត់តាំងផ្សព្វផ្សាយអំពីសភាពការណ៍រួម គោលការណ៍ និងសេចក្តីសម្រេចនានារបស់គណបក្សដល់សមាជិកគណបក្ស និងធ្វើរបាយការណ៍អំពីសភាពការណ៍ ការងារគណបក្ស និងលើកយោបល់ជូនគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលតាមការកំណត់ ។

ខ- **<u>គណៈកម្មាធិការគណបក្សរាជធានី ខេត្ត</u>** មានភារកិច្ច ៥ គឺ :

១. ក្តាប់ជាប់លក្ខន្តិកៈ មាគ៌ា កម្មវិធីនយោបាយរបស់គណបក្ស គោលការណ៍ សេចក្តីសម្រេចចិត្តនានារបស់គណៈកម្មាធិការកណ្តាល និងសេចក្តីសម្រេចចិត្តនៃមហាសន្និបាតគណបក្សរាជធានី ខេត្ត និងក្តាប់ជាប់លក្ខណៈពិសេសនៃសភាពការណ៍ជាក់ស្តែងគ្រប់វិស័យរបស់រាជធានី ខេត្ត ហើយកំណត់ទិសដៅ ភារកិច្ច គោលការណ៍ និងវិធានការអនុវត្តឲ្យបានសមស្រប ព្រមទាំងដឹកនាំគណបក្សក្រុង ស្រុក ខណ្ឌ និងរាល់អង្គការចាត់តាំងគណបក្សចំណុះឲ្យអនុវត្តបានសម្រេចជោគជ័យ ។

២. ដឹកនាំការងារកសាងពង្រឹងគណបក្ស ពីថ្នាក់រាជធានី ខេត្តរហូតដល់មូលដ្ឋាន អំពីវិស័យនយោបាយ សតិអារម្មណ៍ ចាត់តាំង ហិរញ្ញវត្ថុ និងការងារបណ្តុះបណ្តាល រៀបចំ និងគ្រប់គ្រងមន្ត្រីដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន ។

៣. ដឹកនាំការងារកសាងពង្រឹងអង្គការចាត់តាំងមូលដ្ឋានគណបក្ស ការងារគ្រប់គ្រង និងកសាងពង្រីកសមាជិកគណបក្ស និងការងារចលនាមហាជនសំដៅពង្រឹងរាល់សកម្មភាពរបស់គណបក្ស និងប្រមូលផ្តុំបាននូវកម្លាំងគាំទ្រដ៏ទូលំទូលាយអនុវត្តកម្មវិធីនយោបាយ និងគោលការណ៍នានារបស់គណបក្ស ។

៤. ណែនាំក្រើនរំឭកមន្ត្រីគណបក្សដែលត្រូវបានប្រគល់ភារកិច្ចឲ្យទទួលបន្ទុកការងារនៅគ្រប់ស្ថាប័ន មន្ទីរជុំវិញរាជធានី ខេត្ត ព្រមទាំងអង្គភាពផ្សេងៗដែលស្ថិតក្នុងភូមិសាស្ត្ររាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់ការងារគណបក្ស ខិតខំជំរុញការអនុវត្តភារកិច្ចរក្សាស្ថិរភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ភារកិច្ចសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។

៥. ថែរក្សា និងពង្រីកសមិទ្ធផលរបស់គណបក្សនៅគ្រប់មូលដ្ឋាន យកចិត្តទុកដាក់គិតគូរកែលម្អលើកស្ទួយជីវភាពរបស់ប្រជាជន ។

គ- **<u>គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្តាល</u>** មានភារកិច្ច ៦ គឺ :

១. ផ្អែកលើលក្ខន្តិកៈគណបក្ស បទបញ្ជាផ្ទៃក្នុង កម្មវិធីនយោបាយ គោលការណ៍ សេចក្តីកំណត់នានារបស់គណបក្ស និងច្បាប់បញ្ញត្តិជាធរមាន ដើម្បីផ្សព្វផ្សាយ ណែនាំដល់សមាជិកគណបក្សក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួនចូលរួមអនុវត្តស្របតាមសភាពការណ៍ និងភារកិច្ចជាក់ស្តែងនៃដំណាក់កាលនីមួយៗ ។

២. ចាត់តាំងអនុវត្តរបបប្រជុំជីវភាពសមាជិកគណបក្ស ថែបំប៉ន អប់រំ ពង្រឹងសមាជិកគណបក្សខាងនយោបាយ សតិអារម្មណ៍ លើកកម្ពស់គុណធម៌ សីលធម៌ស្អាតស្អំ ថែរក្សាសាមគ្គីភាព ឯកភាពផ្ទៃក្នុង និងចូលរួមអនុវត្តកម្មវិធីនយោបាយ សេចក្តីសម្រេចនានារបស់គណបក្ស ។

៣. លើកឡើងនូវគោលការណ៍ វិធានការ ដើម្បីពង្រឹងការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីនៅក្នុងអង្គការតុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ សំដៅធានាបានទាំងបរិមាណ និងគុណភាព ។

៤. រួមសហការជាមួយគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីពង្រឹងគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីនៅក្នុងអង្គការតុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ នៅគ្រប់ថ្នាក់ ។

៥. ណែនាំភារកិច្ចជាក់ស្តែង និងកំណត់អំពីទំនាក់ទំនងរវាងគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស ជាមន្ត្រីនៅក្នុងអង្គការតុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិបណ្តាថ្នាក់ ស្របតាមរចនាសម្ព័ន្ធនៃការគ្រប់គ្រងសមាជិកគណបក្ស ។

៦. លើកសំណើជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលសម្រេចអំពីការរៀបចំក្រុមសមាជិកគណបក្ស ជាមន្ត្រីនៅក្នុងអង្គការតុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ ឲ្យចូលរួមជីវភាពគណបក្ស ចំណុះអង្គការចាត់តាំងគណបក្សណាមួយ ស្របតាមលក្ខន្តិកៈគណបក្ស ។

ឃ- **<u>ក្រុមការងារគណបក្សចុះមូលដ្ឋាន</u>** មានភារកិច្ចសំខាន់ ៣ គឺគាំទ្រ និងចូលរួមជាមួយអង្គការចាត់តាំងគណបក្សនៅមូលដ្ឋាន ដើម្បី :

១. ពង្រឹងអង្គការចាត់តាំងគណបក្សនៅថ្នាក់ក្រោមជាតិ ទាំងវិស័យ នយោបាយ សតិអារម្មណ៍ ចាត់តាំង និងហិរញ្ញវត្ថុ ។

- ពង្រឹងគណបក្សលើវិស័យនយោបាយ គឺធ្វើឲ្យអង្គការចាត់តាំងគណបក្សគ្រប់ថ្នាក់បានយល់ជ្រួតជ្រាបច្បាស់អំពីកម្មវិធីនយោបាយ គោលនយោបាយ គោលការណ៍ និងសេចក្តីសម្រេចនានារបស់គណបក្ស ហើយផ្អែកលើមូលដ្ឋាននោះ ដាក់ចេញនូវផែនការ និងវិធានការនានា ដើម្បីដឹកនាំអនុវត្តឲ្យទៅជាសកម្មភាពជាក់ស្តែងប្រកបដោយប្រសិទ្ធភាព ។

- ពង្រឹងគណបក្សលើវិស័យសតិអារម្មណ៍ គឺត្រូវឃោសនាអប់រំសមាជិកគណបក្ស និងប្រជាជន ឲ្យបានយល់ដឹងអំពីសភាពការណ៍រីកចម្រើនរបស់ប្រទេសជាតិ អំពីកម្មវិធីនយោបាយ គោលនយោបាយ គោលការណ៍នានារបស់គណបក្ស អំពីភាពជាម្ចាស់របស់ប្រជាជន ដើម្បីពង្រឹងជំនឿលើការដឹកនាំរបស់គណបក្ស និងចូលរួមចំណែកយ៉ាងសកម្មក្នុងសកម្មភាពរបស់គណបក្ស និងការពារគណបក្សនៅគ្រប់កាលៈទេសៈ ។ ជាមួយគ្នានេះ ត្រូវខិតខំតាមដានសភាពការណ៍សកម្មភាពគណបក្សដទៃ ពិសេសក្រុមដែលមាននិន្នាការប្រឆាំង ដើម្បីមានវិធានការទប់ស្កាត់ ឆ្លើយតបចំពោះរាល់សកម្មភាព និងឧបាយកលដែលប៉ះពាល់មកលើគណបក្សយើង និងរាំងស្កាត់ឧបាយកលបំផ្លិចបំផ្លាញរបស់ពួកប្រឆាំង និងពួកអមិត្តនានាចំពោះគណបក្សយើង ។

- ពង្រឹងគណបក្សលើវិស័យចាត់តាំង គឺត្រូវពង្រឹងរចនាសម្ព័ន្ធ អង្គការចាត់តាំងគណបក្សមូលដ្ឋានពិសេសថ្នាក់ឃុំ សង្កាត់ ភូមិ ដើម្បីគ្រប់គ្រង ពង្រឹងពង្រីកសមាជិក និងអ្នកគាំទ្រគណបក្សព្រមទាំងធ្វើបច្ចុប្បន្នភាពសមាជិកគណបក្សឲ្យបានជាប់ជាប្រចាំ ។

- ពង្រឹងគណបក្សលើវិស័យហិរញ្ញវត្ថុ គឺត្រូវកៀរគរមធ្យោបាយ សម្ភារៈ ថវិកា ពីប្រភពស្របច្បាប់នានា ដើម្បីបម្រើសកម្មភាពនយោបាយរបស់គណបក្ស ។

២. រៀបចំផែនការសកម្មភាព ដើម្បីអនុវត្តផែនការឆ្ពោះទៅកាន់ការបោះឆ្នោតនីមួយៗ តាមសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ។

៣. ធ្វើជាស្នូលនៃសាមគ្គីភាព ឯកភាពផ្ទៃក្នុងរបស់គណបក្ស និងធ្វើជាគំរូដល់សមាជិក និងអ្នកគាំទ្រគណបក្ស ក៏ដូចជាមហាជនទូទៅ ព្រមទាំងខិតខំកសាងទំនាក់ទំនងល្អជាមួយមហាជន និងធ្វើអំពើល្អជាមួយប្រជាជនគ្រប់មជ្ឈដ្ឋាន សំដៅលើកកម្ពស់ប្រជាប្រិយភាពរបស់គណបក្ស ក៏ដូចជាដើម្បីទាក់ទាញការគាំទ្របន្ថែមទៀតពីសំណាក់មហាជនចំពោះគណបក្សយើង ។

* ជាមួយគ្នានេះ ប្រធានក្រុមការងារគណបក្សចុះមូលដ្ឋាន រាជធានី ខេត្ត មានភារកិច្ចជួយផ្ដល់យោបល់ដល់គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្នុងការរៀបចំ ការតែងតាំងដំឡើងឋានៈ សម្រួលភារកិច្ចមន្ត្រីគណបក្ស ដែលត្រូវស្នើសុំការសម្រេចពីគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល ។

ក្នុងការអនុវត្តការងាររបស់ខ្លួន ក្រុមការងារគណបក្សចុះមូលដ្ឋាន ត្រូវខិតខំជួយគាំទ្រ បំពាក់បំប៉នពង្រឹងសមត្ថភាពដល់មន្ត្រីគណបក្សនៅមូលដ្ឋាន សំដៅលើកកម្ពស់ភាពជាម្ចាស់ និងស្មារតីទទួលខុសត្រូវរបស់មន្ត្រីគណបក្ស និងអង្គការចាត់តាំងគណបក្សនៅមូលដ្ឋាន ក្នុងការចាត់ចែងដោយផ្ទាល់នូវការងារគណបក្សស្របតាមតួនាទី ភារកិច្ច ការទទួលខុសត្រូវដែលគណបក្សបានកំណត់ ។ ក្រុមការងារគណបក្សចុះមូលដ្ឋានមិនត្រូវធ្វើការសម្រេចចិត្ត ឬចាត់ចែងភារកិច្ចជំនួសអង្គការចាត់តាំងគណបក្សនៅមូលដ្ឋានឡើយ ។

- <u>**ភារកិច្ចក្នុងការពង្រឹងអង្គការមូលដ្ឋានគណបក្ស និងពង្រឹងសមាជិកគណបក្ស**</u>

ត្រូវក្ដាប់ជាប់ទិសដៅពង្រឹងអង្គការមូលដ្ឋានគណបក្ស គឺពង្រឹងទាំងអង្គការចាត់តាំង និងសមាជិកគណបក្ស ហើយត្រូវផ្អែកលើអង្គការចាត់តាំងដើម្បីពង្រឹងសមាជិក ។

* **ត្រូវពង្រឹងគណៈកម្មាធិការគណបក្សមូលដ្ឋាន** ឲ្យមានកម្លាំង និងសមត្ថភាពគ្រប់គ្រាន់ដើម្បីដឹកនាំការងារនៅមូលដ្ឋានរបស់ខ្លួនដោយត្រូវយកចិត្តទុកដាក់ :

១. រៀបចំរចនាសម្ព័ន្ធចាត់តាំងឲ្យមានគ្រប់ចំនួនតាមគោលការណ៍កំណត់

២. ថែបំប៉នជាប្រចាំខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង

៣. ក្ដាប់ជាប់តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួន

៤. បែងចែកភារកិច្ចឲ្យសមាជិកម្នាក់ៗទទួលខុសត្រូវច្បាស់លាស់

៥. មានរបៀបរបបធ្វើការងារបានត្រឹមត្រូវ ម៉ត់ចត់

៦. គ្រប់គ្រង ថែទាំ ប្រើប្រាស់ហិរញ្ញវត្ថុគណបក្សឲ្យមានតម្លាភាព ប្រសិទ្ធភាព និងសន្សំសំចៃ

៧. មានសាមគ្គីភាព ឯកភាពនៅផ្ទៃក្នុងអង្គការចាត់តាំងរបស់ខ្លួន ។

* **ត្រូវពង្រឹងរបបប្រជុំជីវភាព និងការអនុវត្តភារកិច្ចទាំង ៤ របស់សាខាគណបក្ស** :

១. ក្ដាប់ជាប់នូវកម្មវិធីនយោបាយរបស់គណបក្ស និងច្បាប់របស់រដ្ឋ ដើម្បីចាត់តាំងអនុវត្តឲ្យបានសមស្របតាមសភាពការណ៍ជាក់ស្ដែងនៃមូលដ្ឋានរបស់ខ្លួន ។

២. សហការជាមួយអង្គការសង្គម ដើម្បីឃោសនាបំផុសចលនាប្រជាជន ចូលរួមកសាងពង្រឹងរដ្ឋអំណាច យកចិត្តទុកដាក់ដោះស្រាយជីវភាពរស់នៅ ទាំងស្មារតី និងសម្ភារៈដល់ប្រជាជន ។

៣. បែងចែក និងត្រួតពិនិត្យការងាររបស់សមាជិកម្នាក់ៗ អប់រំសមាជិក និងថែរក្សាសាមគ្គីភាព ។

៤. ធ្វើរបាយការណ៍អំពីសភាពការណ៍ និងសុំយោបល់សម្រេចពីថ្នាក់លើនូវបញ្ហាសំខាន់ៗ ។

* **ត្រូវពង្រឹងសមាជិកគណបក្ស** ឲ្យមានគោលជំហរជឿជាក់លើការដឹកនាំរបស់គណបក្ស ជំហរស្នេហាជាតិ និងគោរពស្រឡាញ់ប្រជាជន មានការយល់ដឹងអំពីកម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយរបស់គណបក្ស ហើយធ្វើជាស្នូលក្នុងការអនុវត្តនៅមូលដ្ឋានរបស់ខ្លួន ។ សមាជិកគណបក្សត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ទៅបោះឆ្នោតជូនគណបក្ស និងចេះចលនាញាតិមិត្តអ្នកជិតខាងឲ្យគាំទ្រ និងបោះឆ្នោតជូនគណបក្ស ។

III. **អំពីសិទ្ធិសម្រេចរបស់គណៈកម្មាធិការគណបក្ស**

ក- **គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលមានភារកិច្ចសម្រេច** :

១. តែងតាំងមន្ត្រីគណបក្សថ្នាក់ :

+ ប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត គណបក្សនៅក្រៅប្រទេស និងទីប្រឹក្សាគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ។

+ ប្រធាន និងសមាជិកគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ។

+ ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការត្រួតពិនិត្យ និងគណៈកម្មាធិការហិរញ្ញវត្ថុគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត និងគណបក្សនៅក្រៅប្រទេស ។

+ ប្រធានមន្ទីរគណបក្ស និងប្រធានគណៈចាត់តាំង គណៈឃោសនាអប់រំ គណៈចលនាមហាជននៃគណបក្សរាជធានី ខេត្ត ។

+ សមាជិកយុវជនគណបក្សថ្នាក់កណ្តាល និងជាប្រធានយុវជនគណបក្សថ្នាក់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ។

+ ប្រធានគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ ។

+ ប្រធានសាខាគណបក្សប្រចាំប្រទេស នៅកន្លែងដែលមិនទាន់បង្កើតគណៈកម្មាធិការគណបក្ស ។

២. យល់ព្រមបញ្ចូលសមាជិកគណបក្សក្នុងករណីពិសេសចំពោះឥស្សរជនដែលមានឥទ្ធិពលក្នុងសង្គម មន្ត្រីជាន់ខ្ពស់នៃគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភា ព្រឹទ្ធសភា ចាប់ពីថ្នាក់សមាជិកគណៈកម្មាធិការនាយក នាយទាហានជាន់ខ្ពស់ នាយនគរបាលជាន់ខ្ពស់ និងមន្ត្រីដែលជាសមាជិកគណបក្សនយោបាយនានា ចាប់ពីថ្នាក់អនុប្រធាននាយកដ្ឋាន និងប្រធានមន្ទីរជុំវិញរាជធានី ខេត្ត ឬថ្នាក់ប្រហាក់ប្រហែលឡើងទៅ ។

៣. ជ្រើសរើសសមាជិកគណបក្សឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ បេក្ខជនសមាជិកព្រឹទ្ធសភា បេក្ខជនក្រុមប្រឹក្សារាជធានី ខេត្ត ។

៤. ជ្រើសរើសសមាជិកគណបក្សចូលកាន់មុខនាទីក្នុងរាជរដ្ឋាភិបាល និងស្ថាប័នរបស់រដ្ឋ ។

* **អំពីសំណុំបែបបទស្នើសុំរៀបចំមន្ត្រីគណបក្ស** ត្រូវមាន :

- សំណើរបស់គណៈកម្មាធិការគណបក្ស ។
- កំណត់ហេតុប្រជុំគណៈកម្មាធិការគណបក្ស ឬការផ្តល់មតិជាលាយលក្ខណ៍អក្សរ ដោយមានមតិឯកភាពភាគច្រើនដាច់ខាតនៃគណៈកម្មាធិការគណបក្សទាំងមូល ។
- បញ្ជីវត្តមានចូលរួមប្រជុំ ។
- ប្រវត្តិរូបមន្ត្រីដែលត្រូវបានស្នើសុំតែងតាំង មានបិទរូបថត និងមានឯកសារបញ្ជាក់ពីថ្ងៃចូលជាសមាជិកគណបក្ស ។
- មតិឯកភាពរបស់ប្រធានក្រុមការងារគណបក្សចុះមូលដ្ឋាន រាជធានី ខេត្ត ។

ខ- **គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន មានសិទ្ធិសម្រេច** :

១. សម្រេចបង្កើត រំសាយ និងរៀបចំសមាសភាពគណៈកម្មាធិការគណបក្សមូលដ្ឋានចំណុះ ។

២. សម្រេចបង្កើត រំសាយ និងរៀបចំសមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសាខាគណបក្សចំណុះ ។

៣. សម្រេចប្រគល់ភារកិច្ចជូនសមាជិកគណៈអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័នឲ្យទទួលបន្ទុកការងារនីមួយៗរបស់គណបក្ស ឬជាប្រធាន អនុប្រធាន និងសមាជិកគណៈចាត់តាំង គណៈឃោសនាអប់រំ គណៈចលនាមហាជន និងទទួលបន្ទុកដឹកនាំពង្រឹងអង្គការចាត់តាំងគណបក្ស និងផ្នែកចំណុះ ។

៤. សម្រេចតែងតាំងអនុប្រធាន និងសមាជិកយុវជនគណបក្សថ្នាក់ក្រសួង ស្ថាប័ន និងប្រធានយុវជនគណបក្សថ្នាក់មូលដ្ឋានចំណុះ ។

៥. សម្រេចយល់ព្រមបញ្ចូលសមាជិកគណបក្សក្នុងករណីពិសេស ចំពោះមន្ត្រីដែលមានឋានៈប្រធានការិយាល័យ ឬថ្នាក់ប្រហាក់ប្រហែលចុះ ។

៦. សម្រេចតែងតាំង ដំឡើងឋានៈ ប្រគល់ភារកិច្ច លើកសរសើរ និងដាក់វិន័យចំពោះមន្ត្រីគណបក្សដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងផ្ទាល់

៧. លើកសំណើសុំសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល អំពីការរៀបចំសមាសភាពគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ។

៨. លើកសំណើសុំសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល អំពីការបង្កើត និងតែងតាំងសមាសភាពគណៈកម្មាធិការត្រួតពិនិត្យ និងគណៈកម្មាធិការហិរញ្ញវត្ថុគណបក្សក្រសួង ស្ថាប័ន ។

៩. លើកសំណើសុំសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ចំពោះសំណើសុំចូលជាសមាជិកគណបក្សក្នុងករណីពិសេសរបស់ឥស្សរជនដែលមានឥទ្ធិពលក្នុងសង្គម មន្ត្រីជាន់ខ្ពស់នៃគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភា ព្រឹទ្ធសភា ចាប់ពីថ្នាក់សមាជិកគណៈកម្មាធិការនាយក នាយទាហានជាន់ខ្ពស់ នាយនគរបាលជាន់ខ្ពស់ និងមន្ត្រីដែលមានឋានៈអនុប្រធាននាយកដ្ឋាន ឬថ្នាក់ប្រហាក់ប្រហែលឡើងទៅ ។

១០.រួមយោបល់អំពីការងាររៀបចំមន្ត្រីគណបក្សចូលកាន់មុខនាទីក្នុងស្ថាប័ន អង្គភាពចំណុះក្រសួង ស្ថាប័ន ។

១១.រួមយោបល់អំពីការរៀបចំមន្ត្រីគណបក្សចូលកាន់មុខនាទីជាប្រធានមន្ទីរជំនាញនៃក្រសួង ស្ថាប័ននៅរាជធានី ខេត្ត ។ ក្នុងករណីមានយោបល់ខុសគ្នារវាងគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន និងគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ត្រូវរាយការណ៍ជូនគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលពិនិត្យសម្រេច ។

គ- **<u>គណៈកម្មាធិការគណបក្សរាជធានី ខេត្ត មានសិទ្ធិសម្រេច</u> :**

១. សម្រេចបង្កើត រំសាយ និងរៀបចំសមាសភាពគណៈកម្មាធិការគណបក្សមូលដ្ឋានចំណុះ សាខាគណបក្សចំណុះផ្ទាល់ សាខាគណបក្សពិសេស និងគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះ ។

២. សម្រេចតែងតាំងសមាសភាពគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ ចាប់ពីថ្នាក់អនុប្រធានចុះ ។

៣. សម្រេចតែងតាំងសមាសភាពគណៈកម្មាធិការត្រួតពិនិត្យ និងគណៈកម្មាធិការហិរញ្ញវត្ថុនៃគណបក្សក្រុង ស្រុក ខណ្ឌ ។

៤. សម្រេចតែងតាំងមន្ត្រីគណបក្សចំណុះផ្ទាល់ ចាប់ពីថ្នាក់អនុប្រធានគណៈ និងអនុប្រធានមន្ទីរគណបក្សរាជធានី ខេត្តចុះ ។

៥. សម្រេចតែងតាំងប្រធានគណៈ និងផ្នែកចំណុះគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ ។

៦. សម្រេចតែងតាំង អនុប្រធាន និងសមាជិកយុវជនគណបក្សថ្នាក់រាជធានី ខេត្ត និងប្រធានយុវជនគណបក្សថ្នាក់ក្រុង ស្រុក ខណ្ឌ ។

៧. សម្រេចតែងតាំងប្រធានគណៈកម្មាធិការគណបក្សមូលដ្ឋាន ប្រធានគណៈកម្មាធិការគណបក្សឃុំ សង្កាត់ និងប្រធានស្នាក់ការបក្សឃុំ សង្កាត់ ។

៨. សម្រេចយល់ព្រមបញ្ចូលសមាជិកគណបក្សក្នុងករណីពិសេសចំពោះមន្ត្រីដែលមានឋានៈអនុប្រធានមន្ទីរជុំវិញរាជធានី ខេត្ត ឬថ្នាក់ប្រហាក់ប្រហែលចុះ ។

៩. សម្រេចតែងតាំង ដំឡើងឋានៈ ប្រគល់ភារកិច្ច លើកសរសើរ និងដាក់វិន័យចំពោះមន្ត្រីគណបក្សដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងផ្ទាល់ ។

១០.លើកសំណើសុំសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល អំពីការរៀបចំសមាសភាពគណៈកម្មាធិការគណបក្សរាជធានី ខេត្ត និងប្រធានគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ ។

១១.លើកសំណើសុំសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល អំពីការបង្កើត និងតែងតាំងសមាសភាពគណៈកម្មាធិការត្រួតពិនិត្យ និងគណៈកម្មាធិការហិរញ្ញវត្ថុគណបក្សរាជធានី ខេត្ត ។

១២.លើកសំណើសុំសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ចំពោះសំណើសុំចូលជាសមាជិកគណបក្សក្នុងករណីពិសេសរបស់ឥស្សរជនដែលមានឥទ្ធិពលក្នុងសង្គម មន្ត្រីជាន់ខ្ពស់នៃគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភា ព្រឹទ្ធសភា ចាប់ពីថ្នាក់សមាជិកគណៈកម្មាធិការនាយក នាយទាហានជាន់ខ្ពស់ នាយនគរបាលជាន់ខ្ពស់ និងមន្ត្រីដែលមានឋានៈប្រធានមន្ទីរ ឬថ្នាក់ប្រហាក់ប្រហែលឡើងទៅ ។

១៣.លើកសំណើអំពីបេក្ខភាពមន្ត្រីគណបក្សសម្រាប់ស្នើសុំតែងតាំងមុខតំណែងក្នុងរចនាសម្ព័ន្ធរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរចនាសម្ព័ន្ធប្រធានមន្ទីរ អង្គភាពនានានៅថ្នាក់ក្រោមជាតិ ។

១៤.ចូលរួមយោបល់អំពីការរៀបចំមន្ត្រីគណបក្សចូលកាន់មុខនាទីក្នុងមន្ទីរ អង្គភាពជុំវិញរាជធានី ខេត្ត ។

**ឃ- <u>គណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ មានសិទ្ធិសម្រេច</u> :**

១. សម្រេចបង្កើត រំសាយ និងរៀបចំសមាសភាពដឹកនាំសាខាគណបក្សចំណុះ និងគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះ ។

២. សម្រេចតែងតាំងសមាសភាពគណៈកម្មាធិការគណបក្សឃុំ សង្កាត់ និងគណៈកម្មាធិការគណបក្សមូលដ្ឋានចំណុះចាប់ពីថ្នាក់អនុប្រធានចុះ ។

៣. សម្រេចតែងតាំងមន្ត្រីគណបក្សនៃបណ្តាគណៈ និងផ្នែកចំណុះផ្ទាល់ ចាប់ពីថ្នាក់អនុប្រធានគណៈ អនុប្រធានផ្នែក អនុប្រធានការិយាល័យចុះ ។

៤. សម្រេចតែងតាំងអនុប្រធាន និងសមាជិកយុវជនគណបក្សថ្នាក់ក្រុង ស្រុក ខណ្ឌ និងប្រធានយុវជនគណបក្សថ្នាក់មូលដ្ឋាន និងឃុំ សង្កាត់ ។

៥. សម្រេចតែងតាំង ដំឡើងឋានៈផ្លាស់ប្តូរភារកិច្ច លើកសរសើរ និងដាក់វិន័យ ចំពោះមន្ត្រីគណបក្សដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងផ្ទាល់ ។

៦. លើកសំណើសុំសេចក្តីសម្រេចរបស់គណៈកម្មាធិការគណបក្សរាជធានី ខេត្ត អំពីការបង្កើត និងតែងតាំងសមាសភាពគណៈកម្មាធិការត្រួតពិនិត្យ និងគណៈកម្មាធិការហិរញ្ញវត្ថុគណបក្សក្រុង ស្រុក ខណ្ឌ ។

៧. លើកសំណើសុំសេចក្តីសម្រេចរបស់គណៈកម្មាធិការគណបក្សរាជធានី ខេត្ត អំពីការតែងតាំងសមាសភាពគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ ចាប់ពីថ្នាក់អនុប្រធានចុះ ប្រធានគណៈកម្មាធិការគណបក្សឃុំ សង្កាត់ និងប្រធានស្នាក់ការគណបក្សឃុំ សង្កាត់ ។

៨. លើកសំណើសុំសេចក្តីសម្រេចរបស់គណៈកម្មាធិការគណបក្សរាជធានី ខេត្ត អំពីការសុំចូលជាសមាជិកគណបក្សក្នុងករណីពិសេស ។

៩. លើកសំណើអំពីបេក្ខភាពមន្ត្រីគណបក្ស សម្រាប់ស្នើសុំតែងតាំងមុខតំណែងនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងការិយាល័យ ផ្នែកនានាជុំវិញក្រុង ស្រុក ខណ្ឌ ។

១០.ចូលរួមយោបល់អំពីការរៀបចំមន្ត្រីគណបក្សចូលកាន់មុខនាទីក្នុងការិយាល័យ និងផ្នែកជំនាញនានាជុំវិញក្រុង ស្រុក ខណ្ឌ ។

ង- <u>គណៈកម្មាធិការគណបក្សឃុំ សង្កាត់ និងមូលដ្ឋាន មានសិទ្ធិសម្រេច</u> :

១. សម្រេចបង្កើត រំសាយ និងរៀបចំអនុសាខាគណបក្ស និងក្រុមបក្សចំណុះ ។

២. សម្រេចលើកសរសើរ និងដាក់វិន័យចំពោះអនុសាខាគណបក្ស ក្រុមបក្ស និងសមាជិកគណបក្ស ។

៣. សម្រេចតែងតាំងអនុប្រធាន និងសមាជិកយុវជនគណបក្សថ្នាក់មូលដ្ឋាន ឃុំ សង្កាត់ និងសមាសភាពក្រុមសកម្មជនយុវជនសាខាគណបក្សចំណុះ ។

៤. សម្រេចយល់ព្រមបញ្ចូលសមាជិកគណបក្ស ។

៥. លើកសំណើជូនគណៈកម្មាធិការគណបក្សថ្នាក់លើ ពិនិត្យសម្រេចអំពីការបង្កើត និងតែងតាំងសមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសាខាគណបក្ស ការលើកសរសើរ ដាក់វិន័យចំពោះគណៈកម្មាធិការសាខាគណបក្ស និងសមាសភាពដឹកនាំសាខាគណបក្ស ។

៦. លើកសំណើសុំសេចក្តីសម្រេចពីគណៈកម្មាធិការគណបក្សថ្នាក់លើអំពីការសុំចូលជាសមាជិកគណបក្សក្នុងករណីពិសេស ។

## IV. <u>អំពីរចនាសម្ព័ន្ធ អង្គភាពចាត់តាំង</u>

### ក- <u>អំពីរចនាសម្ព័ន្ធ</u>

១. **<u>រចនាសម្ព័ន្ធគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត</u>** ត្រូវមានមន្ត្រីគណបក្សជាថ្នាក់ដឹកនាំសំខាន់ៗ វ័យចាស់ វ័យក្មេង នារី ជនជាតិភាគតិច (នៅមូលដ្ឋានដែលមានជនជាតិភាគតិចច្រើន) ដែលមានសមត្ថភាព មានសុខភាពល្អ មានបទពិសោធន៍ការងារគណបក្ស មានលក្ខណសម្បត្តិល្អប្រពៃ មានទស្សនៈគោលជំហរនយោបាយរឹងមាំ មានគុណធម៌ សីលធម៌ល្អ មានទំនាក់ទំនងល្អជាមួយមហាជន មានលទ្ធភាពរ៉ាប់រងការងារគណបក្សដែលបានប្រគល់ជូន ។

២. **<u>សមាសភាពគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន</u>** រួមមានមន្ត្រីគណបក្សជារដ្ឋមន្ត្រី ប្រធាន អនុប្រធានស្ថាប័ន រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សា អគ្គនាយក អគ្គនាយករង អគ្គាធិការ អគ្គាធិការរង ថ្នាក់នាយកដ្ឋាន ឬថ្នាក់ប្រហាក់ប្រហែល ប្រធានគណៈកម្មាធិការគណបក្សមូលដ្ឋាន និងប្រធានគណៈកម្មាធិការសាខាគណបក្សមួយចំនួន ។

ដោយឡែកសមាសភាពគណៈកម្មាធិការគណបក្សនៃក្រសួង ស្ថាប័ន ដែលមានអគ្គនាយកដ្ឋាន អង្គភាព និងថ្នាក់ប្រហាក់ប្រហែលចំណុះច្រើន ត្រូវបានកំណត់រួមមានមន្ត្រីគណបក្សក្នុងតំណែងថ្នាក់អគ្គនាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែលឡើងទៅ និងមន្ត្រីទទួលបន្ទុកលើវិស័យការងារសំខាន់ៗរបស់គណបក្ស ។

គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្ស រួមមានមន្ត្រីគណបក្សជារដ្ឋមន្ត្រី ប្រធានស្ថាប័ន ថ្នាក់ដឹកនាំ និងមន្ត្រីដែលទទួលបន្ទុកលើវិស័យការងារសំខាន់ៗរបស់គណបក្ស និងរបស់ក្រសួង ស្ថាប័ន ។

៣. **<u>សមាសភាពគណៈកម្មាធិការគណបក្សរាជធានី ខេត្ត</u>** រួមមានមន្ត្រីគណបក្សជាអភិបាល អភិបាលរងរាជធានី ខេត្ត (តំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភាដែលចាំបាច់ មន្ត្រីដែលមានបទពិសោធន៍ក្នុងការងារដឹកនាំ និងមានឥទ្ធិពលល្អ) ប្រធានគណៈ ប្រធានមន្ទីរគណបក្ស មន្ត្រីដឹកនាំនៅតាមមន្ទីរ អង្គភាពជុំវិញរាជធានី ខេត្ត ប្រធានគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ អភិបាល និងប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។ ប្រធានគណៈ ឬប្រធានមន្ទីរគណបក្សត្រូវតែជាសមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្ស អនុប្រធានគណៈ ឬអនុប្រធានមន្ទីរគណបក្ស ១រូបទៀត អាចជាសមាជិកគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ។

គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្ស រួមមានមន្ត្រីគណបក្សជាអភិបាល អភិបាលរង (តំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភាដែលចាំបាច់ មន្ត្រីដែលមានបទពិសោធន៍ក្នុងការដឹកនាំ និងមានឥទ្ធិពលល្អ) ប្រធានគណៈ ប្រធានមន្ទីរគណបក្ស មន្ត្រីដឹកនាំនៅក្នុងកងកម្លាំងប្រដាប់អាវុធ និងមន្ទីរ អង្គភាពសំខាន់ៗជុំវិញរាជធានី ខេត្ត ។ ក្នុងករណីចាំបាច់ ប្រធានគណៈកម្មាធិការគណបក្សក្រុង ដែលជាទីតាំងរដ្ឋបាលខេត្ត អាចជាសមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សខេត្ត ។

គណៈប្រចាំការរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សរាជធានី ខេត្ត រួមមានអនុប្រធានគណបក្សរាជធានី ខេត្ត ១រូប ជាប្រធាន និងសមាជិកដែលជាប្រធានគណៈ ប្រធានមន្ទីរគណបក្ស និងមន្ត្រីដែលទទួលបន្ទុកការងារគណបក្ស ។

ជាគោលការណ៍រួម អភិបាលរាជធានី ខេត្ត ត្រូវបានពិនិត្យរៀបចំជាប្រធានគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ។ ករណីជាក់ស្តែងមួយចំនួន ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត អាចត្រូវបានរៀបចំជាប្រធានគណៈកម្មាធិការគណបក្សរាជធានី ខេត្តបាន ។ ចំពោះសមាជិក សមាជិកាព្រឹទ្ធសភា និងតំណាងរាស្ត្រគឺត្រូវបានសម្រួលភារកិច្ចពីគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ហើយបានគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលឧទ្ទេសនាមឲ្យចូលរួមជីវភាពគណបក្សជាមួយគណៈកម្មាធិការគណបក្សរាជធានី ខេត្ត នៃមណ្ឌលបោះឆ្នោតរបស់សាមីខ្លួនរហូតដល់ចប់អាណត្តិ ។

៤. <u>**សមាជិកគណៈកម្មាធិការកណ្តាល**</u> ត្រូវចូលរួមជាសមាជិកគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ដើម្បីចូលរួមចំណែកទទួលខុសត្រូវក្នុងការដឹកនាំការងារគណបក្ស និងចូលរួមក្នុងការកសាងពង្រឹងគណបក្សនៅទីនោះ ។ នៅកន្លែងដែលមានសមាជិកគណៈកម្មាធិការកណ្តាលចំនួន ៣រូបចុះ ត្រូវបែងចែកភារកិច្ចជូនសមាជិកគណៈកម្មាធិការកណ្តាលទាំងអស់ក្នុងជួរគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ។

សមាជិកគណៈកម្មាធិការកណ្តាលដែលត្រូវបានឈប់សម្រាកពីការងារ ត្រូវបានគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលឧទ្ទេសនាមជូនគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ដើម្បីរៀបចំឲ្យចូលរួមជីវភាពគណបក្សជាមួយគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ឬគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ ដែលសាមីខ្លួនរស់នៅ ។

<u>**បញ្ជាក់**</u> : រចនាសម្ព័ន្ធនៃគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមូលដ្ឋាន ត្រូវរៀបចំឲ្យមានសមាសភាពជាស្ត្រីចំនួន ២រូបឡើងទៅ ។

ខ- <u>**អំពីស្ថាប័នជំនួយការគណៈកម្មាធិការគណបក្ស**</u>

១. <u>**ស្ថាប័នជំនួយការគណបក្សក្រសួង ស្ថាប័ន**</u> រួមមាន :

- មន្ទីរគណបក្ស ឬលេខាធិការដ្ឋាន
- គណៈកម្មាធិការត្រួតពិនិត្យ (ចំនួន ៥រូប)
- គណៈកម្មាធិការហិរញ្ញវត្ថុ
- យុវជនគណបក្សថ្នាក់ក្រសួង ស្ថាប័ន ។

គណបក្សក្រសួង ស្ថាប័ន ត្រូវបែងចែកភារកិច្ចជូនសមាជិកគណៈកម្មាធិការគណបក្សទទួលបន្ទុកការងារជំនាញចាត់តាំង ឃោសនាអប់រំ ចលនាមហាជន ឬសម្រេចបង្កើតគណៈជំនាញទាំងនេះ និងតែងតាំងមន្ត្រីជំនួយការការងារជំនាញគណបក្សតាមការចាំបាច់ ។

២. <u>**ស្ថាប័នជំនួយការគណបក្សរាជធានី ខេត្ត**</u> រួមមាន :

- មន្ទីរគណបក្ស

- គណៈចាត់តាំង
- គណៈឃោសនាអប់រំ
- គណៈកម្មាធិការត្រួតពិនិត្យ (ចំនួន ៥រូប ឬ ៣រូប)
- គណៈកម្មាធិការហិរញ្ញវត្ថុ
- គណៈចលនាមហាជន
- យុវជនគណបក្សថ្នាក់រាជធានី ខេត្ត ។

គ- **អំពីបរិមាណសមាជិកគណៈកម្មាធិការគណបក្ស** :

១. **គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន** :

- មានចំនួន ៨៣រូបចុះ ចំពោះក្រសួង ស្ថាប័ន ដែលមានគណៈកម្មាធិការគណបក្សមូលដ្ឋានចំណុះចំនួន ៧ឡើងទៅ
- មានចំនួន ៧១រូបចុះ ចំពោះក្រសួង ស្ថាប័ន ដែលមានគណៈកម្មាធិការគណបក្សមូលដ្ឋានចំណុះចំនួន ៦ចុះ
- មានចំនួន ៥៩រូបចុះ ចំពោះក្រសួង ស្ថាប័ន ដែលមានតែនាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែលចំណុះ (មិនមានអគ្គនាយកដ្ឋាន) ។

\+ គណៈអចិន្ត្រៃយ៍មានចំនួនមិនលើស ១ភាគ៣ នៃចំនួនសមាជិកគណៈកម្មាធិការគណបក្ស ។

\+ អនុប្រធានគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ត្រូវមានចំនួន ១ ទៅ ២ រូប ។

ដោយឡែកចំពោះក្រសួង ស្ថាប័ន ដែលមានគណៈកម្មាធិការគណបក្សមូលដ្ឋាន និងគណៈកម្មាធិការសាខាគណបក្សចំណុះផ្ទាល់ចំនួន ១២ ឡើងទៅ អាចរៀបចំឲ្យមានអនុប្រធាន ៣ រូប ។ ក្រសួង ស្ថាប័ន ដែលមានគណៈកម្មាធិការគណបក្សមូលដ្ឋាន និងគណៈកម្មាធិការសាខាគណបក្សចំណុះផ្ទាល់ចំនួន ១៨ ឡើងទៅ អាចរៀបចំឲ្យមានអនុប្រធាន ៤ រូប ។

២. **គណៈកម្មាធិការគណបក្សរាជធានី ខេត្ត** :

- មានចំនួន ៥១រូបចុះ ចំពោះរាជធានី ខេត្តចំនួន ១៤ : ភ្នំពេញ កំពង់ចាម ត្បូងឃ្មុំ ព្រៃវែង កណ្តាល តាកែវ សៀមរាប កំពង់ស្ពឺ ស្វាយរៀង បាត់ដំបង កំពត កំពង់ធំ បន្ទាយមានជ័យ កំពង់ឆ្នាំង
- មានចំនួន ៤៩រូបចុះ ចំពោះខេត្តចំនួន ៦ : ពោធិ៍សាត់ ក្រចេះ ព្រះវិហារ រតនគិរី ស្ទឹងត្រែង កោះកុង
- មានចំនួន ៤៣រូបចុះ ចំពោះខេត្តចំនួន ៥ : មណ្ឌលគិរី ឧត្តរមានជ័យ ព្រះសីហនុ កែប ប៉ៃលិន ។

\+ គណៈអចិន្ត្រៃយ៍មានចំនួន ១៧-១៥-១៣រូបចុះ តាមប្រភេទរាជធានី ខេត្តទាំង ៣ ។

\+ អាចពង្រីកបន្ថែមបរិមាណសមាជិកគណៈកម្មាធិការគណបក្ស នៅក្នុងជួរសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត និងបង្កើនបរិមាណសមាជិកគណៈអចិន្ត្រៃយ៍ តែមិនឲ្យលើស ១ភាគ៣ នៃចំនួនសមាជិកគណៈកម្មាធិការគណបក្ស ។

\+ អនុប្រធានគណៈកម្មាធិការគណបក្សមានចំនួន ២រូប ។ រាជធានី ខេត្តចំនួន ១៤ ខាងដើមអាចរៀបចំឱ្យមានអនុប្រធាន ៣រូប ។

\+ គណៈប្រចាំការមានចំនួន ៧រូបចុះ ហើយត្រូវតិចជាងពាក់កណ្តាលនៃចំនួនសមាជិកគណៈអចិន្ត្រៃយ៍ ។

ឃ- **គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវបានបោះឆ្នោតជ្រើសតាំងដោយមហាសន្និបាតគណបក្សថ្នាក់ខ្លួន** ហើយបានគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលចេញសេចក្តីសម្រេចយល់ព្រមទទួលស្គាល់តាមលទ្ធផលនៃការបោះឆ្នោត ស្របតាមគោលការណ៍កំណត់របស់គណបក្ស ។

ក្នុងករណីដែលពុំអាចបើកមហាសន្និបាតបាន គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវប្រជុំពេញអង្គដើម្បីលើកសំណើសុំរៀបចំ កែសម្រួល និងតែងតាំងសមាសភាពនៃគណៈកម្មាធិការគណបក្សថ្នាក់ខ្លួន ដាក់ជូនគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលពិនិត្យសម្រេច ។

សំណើសុំរៀបចំ កែសម្រួល និងតែងតាំងមន្ត្រីគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវស្របតាមគោលការណ៍អំពីរចនាសម្ព័ន្ធ លក្ខណសម្បត្តិមន្ត្រី សមាសភាព និងបរិមាណកំណត់ ។ ចំពោះគណៈកម្មាធិការគណបក្សដែលមានគ្រប់បរិមាណកំណត់រួចហើយ ប្រសិនបើមានការតែងតាំងមន្ត្រីជាថ្នាក់ដឹកនាំថ្មី អាចលើកសំណើសុំតែងតាំងបន្ថែមនូវថ្នាក់ដឹកនាំសំខាន់ៗមួយចំនួនជាសមាជិកគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ស្របតាមគោលការណ៍កំណត់អំពីរចនាសម្ព័ន្ធ ។

ង- <u>**លក្ខណសម្បត្តិមន្ត្រីគណបក្ស**</u> មាន ៤ យ៉ាងគឺ :

- មានគោលជំហរស្មោះត្រង់ដាច់ខាតចំពោះគណបក្ស និងផលប្រយោជន៍ជាតិ និងប្រជាជន គឺត្រូវមានស្មារតីតស៊ូការពារគណបក្ស ហ៊ានធ្វើពលិកម្មដើម្បីផលប្រយោជន៍ជាតិ និងប្រជាជន
- មានសុខភាពអាចបំពេញភារកិច្ចបាន
- មានសមត្ថភាពទទួលរ៉ាប់រងសម្រេចបាននូវភារកិច្ចដែលបានប្រគល់ជូន គឺត្រូវមានការយល់ដឹងអំពីទស្សនៈ គោលការណ៍ មាគ៌ានយោបាយគណបក្ស និងចាត់តាំងអនុវត្តដោយជោគជ័យ
- មានប្រជាប្រិយភាព ទទួលបានការគាំទ្រនៅក្នុងគណបក្ស និងពីមហាជន ប្រជាជន គឺត្រូវមានគុណធម៌ល្អប្រពៃ មានភាពជាគំរូទាំងក្នុងជីវភាព និងគោរពអង្គការវិន័យចាត់តាំង ថែរក្សាសាមគ្គីភាពឯកភាពផ្ទៃក្នុងបក្ស ។

## V. <u>**អំពីរបៀបរបបធ្វើការ**</u>

ក- <u>**គណៈកម្មាធិការគណបក្ស**</u> :

គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ដឹកនាំការងារគណបក្សឆ្លងតាមរយៈសន្និបាត ឬប្រជុំពេញអង្គ ១ខែម្តង ។ កាងារសំខាន់ៗដែលត្រូវដាក់ជូនគណៈកម្មាធិការគណបក្សសម្រេច រួមមាន :

១. សភាពការណ៍ ទិសដៅ ភារកិច្ចនយោបាយ និងវិធានការចាត់តាំងអនុវត្តសេចក្តីសម្រេចចិត្ត និងគោលការណ៍សំខាន់ៗរបស់គណៈកម្មាធិការកណ្តាល និងសេចក្តីសម្រេចចិត្តនៃមហាសន្និបាតគណបក្សថ្នាក់ខ្លួន ។

២. របាយការណ៍បូកសរុបវាយតម្លៃសភាពការណ៍ការងារគណបក្ស និងទិសដៅ ភារកិច្ច ផែនការប្រចាំឆមាស ប្រចាំឆ្នាំ របស់គណៈកម្មាធិការគណបក្ស ។

៣. គោលការណ៍ថ្មីសំខាន់ៗអំពីការងារគណបក្ស ។

៤. សំណើរៀបចំសមាសភាពគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត និងសំណើរៀបចំមន្ត្រី និងអង្គការចាត់តាំងគណបក្ស ដែលស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងដោយថ្នាក់កណ្តាល និងអំពីការងារគណបក្សដែលមានការលំបាកស្មុគស្មាញ គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត មិនអាចដោះស្រាយបាន ។

៥. ការងារមន្ត្រី និងបញ្ហាទាំងឡាយដែលកំណត់ក្នុងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងគណបក្ស និងកំណត់ដោយគណៈកម្មាធិការកណ្តាល ត្រូវសម្រេចដោយគណៈកម្មាធិការគណបក្ស ។

៦. គោលការណ៍ និងសេចក្តីព្រាងខ្លឹមសារសម្រាប់បើកមហាសន្និបាតគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ។

៧. បញ្ហាផ្សេងៗដែលភាគច្រើននៃសមាជិកគណៈអចិន្ត្រៃយ៍មិនទាន់មានការឯកភាព និងឃើញថាចាំបាច់ត្រូវលើកមកដាក់ជូនគណៈកម្មាធិការគណបក្សពិនិត្យ សម្រេច ។

ខ- <u>គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្ស</u> :

គណអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ទទួលខុសត្រូវដឹកនាំការងារគណបក្ស ក្នុងចន្លោះពេលពីសន្និបាតពេញអង្គមួយ ទៅសន្និបាតពេញអង្គមួយទៀត របស់គណៈកម្មាធិការគណបក្ស ។ គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សប្រជុំក្នុងមួយខែ ២ដង ក្នុងករណីចាំបាច់អាចប្រជុំវិសាមញ្ញ ។

ភារកិច្ចការងាររបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត រួមមាន :

១. ដឹកនាំ ណែនាំ ចាត់តាំងអនុវត្តសេចក្តីសម្រេចចិត្តរបស់គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត និងគោលការណ៍កំណត់ទាំងឡាយរបស់គណៈកម្មាធិការកណ្តាល ។

២. ដឹកនាំការងាររបស់បណ្តាគណៈជំនាញ មន្ទីរគណបក្ស ក្រុមការងារ និងស្ថាប័នជំនួយការរបស់គណៈកម្មាធិការគណបក្ស ។

៣. ដឹកនាំពង្រឹងខ្សែរយៈអង្គការចាត់តាំងរបស់គណបក្ស និងណែនាំត្រួតពិនិត្យការអនុវត្តរាល់ភារកិច្ចការងារគណបក្ស ការងារពង្រឹងមូលដ្ឋាន និងចលនាមហាជន ។

៤. ចាត់តាំងផ្សព្វផ្សាយសភាពការណ៍ភារកិច្ចដល់គណៈកម្មាធិការគណបក្ស និងសាខាគណបក្សចំណុះ និងអនុវត្តរបបរាយការណ៍តាមការកំណត់ ជូនគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ។

៥. កោះប្រជុំ និងត្រៀមរៀបចំខ្លឹមសារសន្និបាត ឬប្រជុំពេញអង្គគណៈកម្មាធិការគណបក្ស និងរាយការណ៍ជូនគណៈកម្មាធិការគណបក្សអំពីសភាពការណ៍ការងារ ដែលគណៈអចិន្ត្រៃយ៍បានសម្រេច ។

គ- <u>គណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សរាជធានី ខេត្ត</u>

គណៈប្រចាំការទទួលខុសត្រូវជំនួសមុខគណៈអចិន្ត្រៃយ៍នៃគណៈម្មាធិការគណបក្សរាជធានី ខេត្ត ដើម្បីដោះស្រាយការងារប្រចាំថ្ងៃរបស់គណបក្សរាជធានី ខេត្ត និងអនុវត្តភារកិច្ចដែលគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សបានប្រគល់ឲ្យ ។ ប្រធានគណៈប្រចាំការត្រូវធ្វើទំនាក់ទំនងជាប្រចាំជាមួយប្រធាន អនុប្រធានគណៈកម្មាធិការគណបក្សដើម្បីរាយការណ៍សុំគោលការណ៍ដឹកនាំ និងត្រួតពិនិត្យដោះស្រាយការងារ ។ គណៈប្រចាំការប្រជុំ ១សប្តាហ៍ម្តង ។

ភារកិច្ចការងាររបស់គណៈប្រចាំការនៃគណៈអចិន្ត្រៃយគណៈកម្មាធិការគណបក្ស រួមមាន :

១. ចាត់តាំងអនុវត្តរាល់គោលការណ៍ សេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ។

២. កំណត់ទិសដៅ ភារកិច្ចជាក់ស្តែង និងត្រួតពិនិត្យការចាត់តាំងអនុវត្តការងាររបស់បណ្តាគណៈជំនាញ និងមន្ទីរគណបក្សរាជធានី ខេត្ត ។

៣. ណែនាំ ត្រួតពិនិត្យការអនុវត្តរាល់ភារកិច្ចការងាររបស់អង្គការចាត់តាំងគណបក្សចំណុះ ។

៤. សម្រេចការតែងតាំង ដំឡើងឋានៈ ប្រគល់ភារកិច្ចចំពោះមន្ត្រីគណបក្សរាជធានី ខេត្ត ចាប់ពីថ្នាក់អនុប្រធានការិយាល័យចុះ ។

៥. សម្រេចការរៀបចំសមាសភាពដឹកនាំគណៈកម្មាធិការគណបក្សមូលដ្ឋាន សាខាគណបក្សចំណុះផ្ទាល់ និងសាខាពិសេស ចាប់ពីថ្នាក់អនុប្រធានចុះ ។

ឃ- <u>ប្រធាន អនុប្រធាន សមាជិកគណៈអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មាធិការគណបក្ស</u>

- ប្រធានគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ទទួលខុសត្រូវដឹកនាំរួម តាមគោលការណ៍ដែលបានសម្រេចដោយគណៈកម្មាធិការគណបក្ស និងគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្ស ។

- អនុប្រធានទទួលខុសត្រូវជួយប្រធានដឹកនាំការងារមួយចំនួនតាមការប្រគល់ភារកិច្ចរបស់ប្រធាន និងគណៈអចិន្ត្រៃយ៍ និងជំនួសប្រធាននៅពេលដែលប្រធានអវត្តមាន ។

- សមាជិកគណៈអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវក្តាប់ជាប់នូវសេចក្តីសម្រេចចិត្ត និងគោលការណ៍នានារបស់គណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការគណបក្ស ដើម្បីដឹកនាំ ណែនាំ និងចាត់តាំងអនុវត្ត នៅតាមផ្នែកការងារ និងអង្គការចាត់តាំងគណបក្សចំណុះ ឬមូលដ្ឋានដែលខ្លួនទទួលខុសត្រូវ ។ ត្រូវមានរបបចុះជួយដល់មូលដ្ឋាន និងអនុវត្តរបបប្រជុំជីវភាពគណបក្សឲ្យបានទៀងទាត់ ក្តាប់ជាប់សភាពការណ៍ និងសំណូមពររបស់មន្ត្រីសមាជិកគណបក្ស និងមហាជន ប្រជាជន ដើម្បីលើកសំណើជូនគណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការគណបក្ស ចេញសេចក្តីសម្រេចចិត្ត គោលការណ៍ វិធានការដឹកនាំរួម ។

- ប្រធាន អនុប្រធាន សមាជិកគណៈអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មាធិការគណបក្ស ចូលរួមប្រាស្រ័យក្នុងការដឹកនាំដោយសមូហភាព តាមរយៈអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍ ឬគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ។ នៅពេលពិភាក្សាការងារ ត្រូវគោរពមតិប្រជាធិបតេយ្យ ។ ក្រោយពេលអនុម័តភាគតិចត្រូវគោរពភាគច្រើន ។ ការអនុម័តរបស់គណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការគណបក្ស កំណត់យកសំឡេងភាគច្រើននៃសមូហភាពគណៈអចិន្ត្រៃយ៍ទាំងមូល និងគណៈកម្មាធិការគណបក្សទាំងមូល លើកលែងតែការអនុវត្តដាក់វិន័យដែលមានការកំណត់ដោយឡែក ៕